# តើហេតុអ្វីបានត្រូវវិនិយោគក្នុងមូលនិធិ មូលបត្រកម្មសិទ្ធិអាស៊ី ប៊ីអេអឹមស៊ី ?




## ចំណុចទាក់ទាញសំខាន់ៗ

ដើមទុនវិនិយោគអប្បបរមា ត្រឹមតែ៥០០ដុល្លារអាមេរិក

ការវិនិយោគធ្វើឡើងដោយការធ្វើពិពិធកម្ម នៅក្នុងគ្រប់វិស័យដែលមានកំណើនទីផ្សារ ខ្ពស់នៅទូទាំងតំបន់អាស៊ី

ការវិនិយោគត្រូវបានគ្រប់គ្រងដោយក្រុម ការងារមានវិជ្ជាជីវៈត្រឹមត្រូវ

ជាមូលនិធិស្ថិតក្រោមនិយ័តកម្ម របស់និយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ដំបូងគេ



## ទំនាក់ទំនង

សម្រាប់ព័ត៌មានបន្ថែមអំពីមូលនិធិមូលបត្រកម្មសិទ្ធិអាស៊ី ប៊ីអេអឹមស៊ី សូមធ្វើការទាក់ទងមកកាន់ក្រុមការងារតាមរយៈ៖

**អេស៊ីលីដា ACLEDA SECURITIES**

(+855) 99 800 879
acledasecurities.com.kh
unit.fsr@acledasecurities.com.kh

**BANJARAN ASSET MANAGEMENT (CAMBODIA)**

(+855) 96 368 8855
banjaranassetmanagement.com.kh
salesmarketing@banjaranassetmanagement.com.kh




RISE OF ASIA
BAMC ASIA EQUITY FUND

ការរីកចម្រើននៃតំបន់អាស៊ី

# មូលនិធិមូលបត្រកម្មសិទ្ធិអាស៊ី ប៊ីអេអឹមស៊ី

វិនិយោគសម្រាប់អនាគត
វិនិយោគនៅក្នុងតំបន់អាស៊ី



# អំពីមូលនិធិមូលបត្រកម្មសិទ្ធិអាស៊ី ប៊ីអេអឹមស៊ី

មូលនិធិមូលបត្រកម្មសិទ្ធិអាស៊ី ប៊ីអេអឹមស៊ី គឺជាគម្រោងមូលនិធិវិនិយោគដែលត្រូវបានបង្កើតឡើង និងគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ ដើម្បីទាញយកផលប្រយោជន៍ពីកំណើនសក្តានុពលនៃសេដ្ឋកិច្ចនាំមុខគេនៅតំបន់អាស៊ី។ ដោយការវិនិយោគធ្វើឡើងនៅក្នុងទីផ្សារភាគហ៊ុនដែលមាននៅតាមបណ្តាប្រទេសនិងវិស័យជាច្រើន មូលនិធិមានគោលបំណងផ្តល់នូវផលចំណេញដ៏គួរឱ្យទាក់ទាញ ខណៈដែលកម្រិតហានិភ័យត្រូវបានកាត់បន្ថយ។

# អំពីយើងខ្ញុំ

## ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

**បេនចារ៉ាន អ៊ែសេត មេនេចម៉ិន (ខេមបូឌា) ម.ក**
**លេខចុះបញ្ជីក្រុមហ៊ុន៖ ២០០០២០៩៩៧៣**

ក្រុមហ៊ុនបេនចារ៉ាន អ៊ែសេត មេនេចម៉ិន (ខេមបូឌា) ម.ក (Banjaran AMC) ត្រូវបានបង្កើតនិងចុះបញ្ជីពាណិជ្ជកម្មក្នុងឆ្នាំ២០២២ ហើយទទួលបានអាជ្ញាបណ្ណជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិពីនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ក្នុងខែមីនា ឆ្នាំ២០២៣។ ក្រុមហ៊ុនបេនចារ៉ាន អ៊ែសេត មេនេចម៉ិន (ខេមបូឌា) ម.ក គឺជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិដំបូងគេនៅកម្ពុជា ដែលបានដាក់ឱ្យដំណើរការលក់ឯកតាមូលនិធិនៅក្នុងប្រទេសកម្ពុជា។

## ទីប្រឹក្សាមូលនិធិ

**BANJARAN ASSET MANAGEMENT PTE. LTD**

ក្រុមហ៊ុន Banjaran Asset Management Pte. Ltd (BAMPL) ដែលមានទីតាំងនៅប្រទេសសិង្ហបុរី ត្រូវបានចាត់តាំងឱ្យធ្វើជាទីប្រឹក្សាផ្នែកវិនិយោគរបស់មូលនិធិមូលបត្រកម្មសិទ្ធិអាស៊ី ប៊ីអេអឹមស៊ី។ ដោយត្រូវបានបង្កើតឡើងនៅចុះបញ្ជីក្នុងឆ្នាំ២០១៤ BAMPL ត្រូវបានស្ថិតក្រោមនិយ័តកម្មរបស់អាជ្ញាធររូបិយវត្ថុសិង្ហបុរី និងទទួលបានអាជ្ញាបណ្ណជាក្រុមហ៊ុនផ្តល់សេវាទីផ្សារមូលធន ដើម្បីប្រតិបត្តិសកម្មភាពពាក់ព័ន្ធនឹងការគ្រប់គ្រងមូលនិធិសម្រាប់អតិថិជនជារូបវន្តបុគ្គល និងនីតិបុគ្គល។

# តើអ្នកណាដែលគួរចូលរួមវិនិយោគ ?

**អ្នកចាប់ផ្តើម៖**
ចាប់ផ្តើមក្នុងទំហំតូច គោលដៅមានទំហំធំ៖ ជាមួយនឹងចំនួន ៥០០ដុល្លារអាមេរិក លោកអ្នកអាចចាប់ផ្តើមវិនិយោគនិងទទួលបានផលចំណេញពីកំណើននៃទីផ្សារសេដ្ឋកិច្ចក្នុងតំបន់អាស៊ី។

**វិនិយោគិនមានបទពិសោធន៍៖**
ការធ្វើពិពិធកម្មដ៏ឆ្លាតវៃ៖ គ្រាន់តែបន្ថែមផលិតផលរបស់មូលនិធិមូលបត្រកម្មសិទ្ធិអាស៊ី ប៊ីអេអឹមស៊ី ទៅកាន់ផលប័ត្ររបស់អ្នក គឺអាចឈានទៅដល់ទីផ្សារដែលមានកំណើនខ្ពស់នៅក្នុងតំបន់អាស៊ី។

**វិនិយោគិនមានផែនការរយៈពេលវែង៖**
វិនិយោគសម្រាប់អនាគត៖ ជាជម្រើសល្អបំផុតសម្រាប់វិនិយោគិនដែលកំពុងស្វែងរកផលចំណេញក្នុងរយៈពេលវែងជាមួយនឹងគោលដៅក្នុងការផ្តល់ផលចំណេញ ៧-១០%* ក្នុងមួយឆ្នាំ។

**អ្នកជំនាញវិជ្ជាជីវៈវ័យក្មេង៖**
បង្កើតទ្រព្យសម្បត្តិក្នុងវ័យក្មេង៖ ចាប់ផ្តើមដំណើរការនៃការវិនិយោគរបស់អ្នកនៅពេលអ្នកមានវ័យក្មេង ជាមួយនឹងចំណុចចាប់ផ្តើមទាប និងរង់ចាំទទួលផលដែលមានកំណើនទៅតាមពេលវេលា។

**វិនិយោគិនសកល៖**
របកគំហើញនូវទីផ្សារថ្មី៖ ធ្វើពិពិធកម្មការវិនិយោគរបស់អ្នក ដោយវិនិយោគនៅក្នុងបណ្តាប្រទេសនិងវិស័យផ្សេងៗគ្នានៅតំបន់អាស៊ី។

**វិនិយោគិនដែលមានហានិភ័យទាប៖**
សមតុល្យរវាងហានិភ័យនិងកំណើន៖ វិធីសាស្ត្រនៃការធ្វើពិពិធកម្មរបស់មូលនិធិមូលបត្រកម្មសិទ្ធិអាស៊ី ប៊ីអេអឹមស៊ីបានជួយគ្រប់គ្រងហានិភ័យក្នុងអំឡុងពេលកំណត់អំពីគោលដៅផ្តល់ផលចំណេញប្រកបដោយស្ថិរភាព។

*ផលចំណេញពីការវិនិយោគ មិនត្រូវបានធានា

# ដៃគូសហការរបស់យើងខ្ញុំ

មូលនិធិមូលបត្រកម្មសិទ្ធិអាស៊ី ប៊ីអេអឹមស៊ី ប្តេជ្ញាធានាឱ្យបាននូវស្តង់ដារខ្ពស់នៃតម្លាភាពសុវត្ថិភាព និងគណនេយ្យភាពសម្រាប់វិនិយោគិនរបស់យើងខ្ញុំ។ កត្តាទាំងនេះហើយទើបក្រុមហ៊ុនយើងខ្ញុំបានសហការជាដៃគូជាមួយនឹងបណ្តាក្រុមហ៊ុនមានកិត្តិនាមដើម្បីធានាឱ្យបាននូវទំនុកចិត្តនិងសុវត្ថិភាពជូនវិនិយោគិនរបស់យើងខ្ញុំ នៅខណៈដែលការវិនិយោគរបស់អតិថិជនកំពុងមានស្ថិរភាពក្នុងការកើនឡើង។

## ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

**ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក**

ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០ ក្រុមហ៊ុនមូលបត្រ អេស៊ីលីដា ម.ក ជាក្រុមហ៊ុនឈ្មួញជើងសាមូលបត្រ ឈានមុខគេរបស់កម្ពុជា ដែលមានអាជ្ញាបណ្ណទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា។ ក្នុងនាមជាក្រុមហ៊ុនបុត្តសម្ព័ន្ធរបស់ធនាគារអេស៊ីលីដាភីអិលស៊ីដែលជាធនាគារចំណាស់និងធំជាងគេរបស់ប្រទេសកម្ពុជាដែលផ្តល់សេវាធនាគារយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជានិងប្រទេសជិតខាង វិនិយោគិនអាចទិញមូលនិធិដោយទំនុកចិត្ត និងទទួលបានជំនាញ និងភាពជឿជាក់នៃគ្រឹះស្ថានហិរញ្ញវត្ថុដែលអាចជឿទុកចិត្តបាន។

## ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស

**ក្រុមហ៊ុនស្រ្តងហូល ត្រាសធី ឯ.ក**

ក្រុមហ៊ុនស្រ្តងហូល ត្រាសធី ឯ.ក គឺជាក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ដែលមានកេរ្តិ៍ឈ្មោះនិងមានបទពិសោធន៍គ្រប់គ្រាន់ ដើម្បីត្រួតពិនិត្យទ្រព្យសម្បត្តិរបស់មូលនិធិ និងធានាថាទ្រព្យសម្បត្តិទាំងនោះ ត្រូវបានគ្រប់គ្រងដោយស្របតាមផលប្រយោជន៍ល្អបំផុតរបស់អ្នកវិនិយោគរបស់យើងខ្ញុំ។ តួនាទីរបស់ក្រុមហ៊ុនស្រ្តងហូល ត្រាសធី ឯ.ក គឺជាអាណាព្យាបាលឯករាជ្យ ការពារទ្រព្យសម្បត្តិរបស់មូលនិធិ និងធានាថាទ្រព្យសម្បត្តិទាំងនោះ ត្រូវបានប្រើប្រាស់សម្រាប់តែផលប្រយោជន៍របស់អ្នកវិនិយោគរបស់យើង។ វត្តមានរបស់ក្រុមហ៊ុនស្រ្តងហូល ត្រាសធី ឯ.ក បានផ្តល់បន្ថែមនូវកម្រិតនៃការធានានិងទំនុកចិត្ត ដោយពង្រឹងការប្តេជ្ញាចិត្តរបស់យើងខ្ញុំចំពោះការអនុវត្តការវិនិយោគប្រកបដោយការទទួលខុសត្រូវ និងសីលធម៌ខ្ពស់។

## ក្រុមហ៊ុនផ្តល់សេវាសវនកម្ម

**ក្រុមហ៊ុន ក្រូវ (ខេអេច) ឯ.ក**

## ក្រុមហ៊ុនផ្តល់សេវាផ្នែកច្បាប់

**ក្រុមហ៊ុនមេធាវី អេច ប៊ី អេស**

